Fact Sheet 3 – Khmer

សន្លឹកហេតុការណ៍ 3

# ការលើកកម្ពស់សមភាពយេនឌ័រ និងការគោរព

**សង្គមអូស្ត្រាលីបានបង្កើតឡើងដោយភាពយុត្តិធម៌ ឱកាស និងជម្រើសសម្រាប់មនុស្សទាំងអស់។ យើងឱ្យតម្លៃស្មើ ភាពគ្នារវាងបុរស និងស្ត្រី ហើយមនុស្សគ្រប់រូបមានសិទ្ធិ ដើម្បីរស់នៅរួចផុតពីអំពើហិង្សា។**

**ការសម្រេចបានសមភាពយេនឌ័រ អាចបង្ការអំពើហិង្សា ប្រឆាំងនឹងស្ត្រី។ ប្រទេសអូស្ត្រាលីមានការជឿនលឿនគួរឱ្យកត់សម្គាល់ឆ្ពោះទៅការសម្រេចសមភាពយេនឌ័រក្នុងប៉ុន្មានទសវត្សថ្មីៗនេះ។**

## សមភាពយេនឌ័រនៅប្រទេសអូស្ត្រាលី

រដ្ឋាភិបាលអូស្ត្រាលី និងរដ្ឋអូស្ត្រាលីខាងត្បូង ធ្វើការជាដៃគូជាមួយ បុគ្គល គ្រួសារ សហគមន៍ កន្លែងធ្វើការ អាជីវកម្ម និងក្រុមសាសនានានាដើម្បីកសាងវប្បធម៌ ការគោរព និងសមភាពដើម្បីជួយបង្ការ អំពើហិង្សាលើដៃគូស្និទ្ធស្នាល គ្រួសារ និងលើផ្លូវភេទ (DFSV)។

រដ្ឋអូស្ត្រាលីខាងត្បូងគឺជាកន្លែងដំបូងគេបង្អស់ ក្នុងប្រទេសអូស្ត្រាលី និងចំណាត់ថ្នាក់ទីបួននៅលើពិភពលោកដែលផ្តល់សិទ្ធិឱ្យស្ត្រីបោះឆ្នោត។ វាក៏ជាកន្លែងដំបូងគេបង្អស់ដែរនៅលើពិភពលោក ដែលផ្តល់ឱកាសសម្រាប់ស្ត្រីក្នុងការឈរឈ្មោះជាតំណាងរាស្ត្រ និងចូលរួមក្នុងការធ្វើឱ្យសង្គមរបស់យើងក្លាយជាអ្នកដឹកនាំ និងអ្នកធ្វើការសម្រេចចិត្ត។

ច្បាប់ប្រទេសអូស្ត្រាលី និងរដ្ឋអូស្ត្រាលីខាងត្បូង លើកកម្ពស់សមភាពនៃឱកាសដើម្បីបង្ការការរើសអើង បង្អាក់ភាពលំអៀង និងអនុញ្ញាតឱ្យប្រជាជនចូលរួមក្នុងជីវិតសាធារណៈ សេដ្ឋកិច្ច និងសង្គមរបស់យើង។ ច្បាប់ទាំងនេះក៏បានផ្តល់នូវកិច្ចការពារផ្នែកច្បាប់ដែរដល់ស្ត្រីពីការរើសអើង និងការយាយីផ្លូវភេទ។

ច្បាប់ទាំងនេះមានន័យថា ស្ត្រីមានសិទ្ធិដើម្បី៖

- មានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ ដោយការរកបាន និងការគ្រប់គ្រងប្រាក់ចំណូលផ្ទាល់របស់ពួកគេ។
- ធ្វើការក្នុងការងារណាមួយ
- ធ្វើឱ្យមានតុល្យភាពការងារ និងការទទួលខុសត្រូវលើការថែទាំ តាមរយៈសិទ្ធិទទួលបាននានា ដូចជាការឈប់សម្រាកដែលមានប្រាក់បៀវត្សរ៍សម្រាប់មាតាបិតានៅពេលកូនកើតមក និង
- រស់នៅដោយគ្មានការរើសអើង និងការយាយីផ្លូវភេទ។

នៅប្រទេសអូស្ត្រាលី មនុស្សគ្រប់រូបមានសិទ្ធិចូលរួមចំណែក និងចូលរួមដោយស្មើភាពគ្នា។ ស្ត្រីចូលរួមក្នុងគ្រប់វិស័យនៃកម្លាំងពលកម្ម ជម្រុញទឹកចិត្តស្ត្រី និងក្មេងស្រីជាទៀតឱ្យសម្រេចបាននូវការពង្រឹងអំណាចខាងសេដ្ឋកិច្ច។

ការផ្តល់លទ្ធភាពឱ្យស្ត្រី អាចឈានទៅរកសក្តានុពលរបស់ពួកគេក្នុងនាមជាអ្នកដឹកនាំ និងអ្នកធ្វើសេចក្តីសម្រេចចិត្តក៏មានសារៈសំខាន់ផងដែរ ដើម្បីទទួលបានសមភាពយេនឌ័រ។ រដ្ឋាភិបាលរដ្ឋអូស្ត្រាលីខាងត្បូងដឹកនាំជាគំរូ ដោយរក្សាការតំណាងស្ត្រី៥០ភាគរយមាននៅក្នុងក្រុមប្រឹក្សា និងគណៈកម្មាធិការរបស់ខ្លួន។

សមិទ្ធផលកីឡារបស់ស្ត្រី ត្រូវបានគេប្រារព្ធពាសពេញប្រទេសអូស្ត្រាលី ហើយប្រជាប្រិយភាពនៃកីឡារបស់ស្ត្រីនៅតែបន្តកើនឡើង ជាពិសេសចាប់តាំងពីមានការណែនាំនៃក្រុមវរជន AFLW សម្ព័ន្ធកីឡាបាល់ទាត់អូស្ត្រាលីសម្រាប់កីឡាករស្ត្រី។

សិទ្ធិ និងការរំពឹងទុកទាំងនេះអនុវត្តចំពោះមនុស្សគ្រប់រូប ដែលរស់នៅក្នុងប្រទេសអូស្ត្រាលី។

## វិសមភាពយេនឌ័រ និងអំពើហិង្សាលើដៃគូស្និទ្ធស្នាល គ្រួសារ និងលើផ្លូវភេទ (DFSV)

ការស្រាវជ្រាវបង្ហាញថាជំនឿរើសអើង និងបង្កអន្តរាយមួយចំនួន បានចូលរួមចំណែកដល់ DFSV៖

- វិសមភាពរវាងបុរស និងស្ត្រី។
- ការរំពឹងទុក និងគំនិតថេរអំពីតួនាទីរបស់បុរស និងស្ត្រី និង
- ឥរិយាបថសង្គមដែលលើកលែងការប្រើអំពើហិង្សា របស់បុរស ចំពោះស្ត្រី។

ជំនឿទាំងនេះអាចបណ្ដាលឱ្យស្ត្រី ត្រូវបានគេប្រព្រឹត្តដោយការគោរព និងសេចក្តីថ្លៃថ្នូរតិចនៅក្នុងទំនាក់ទំនង និងសង្គម។

ការប្រឈមនឹងជំនឿទាំងនេះ និងការផ្លាស់ប្តូរអាកប្បកិរិយាដែលជាប់ទាក់ទង គឺជាគន្លឹះដើម្បីសម្រេចបាននូវសមភាពយេនឌ័រ និងការកាត់បន្ថយ DFSV។

## តើខ្ញុំអាចធ្វើអ្វីបាន?

ឥរិយាបទ ជំនឿ និងអាកប្បកិរិយាដែលគាំទ្រអំពើហិង្សាប្រឆាំងនឹងស្ត្រី ត្រូវបានរៀនដឹង ប៉ុន្តែត្រូវតែមានការប្រឈម ហើយអាចផ្លាស់ប្តូរបាន។

បុគ្គល និងសហគមន៍កំពុងប្រឈមនឹងជំនឿដែលបង្កគ្រោះថ្នាក់ និងចាត់វិធានការដើម្បីបង្ការអាកប្បកិរិយាមិនសមរម្យ និងការរំលោភបំពាន ដោយ៖

- ការចូលរួមក្នុងគំនិតផ្តួចផ្តើមនានា ដែលលើកកម្ពស់ការគោរព រវាងបុរស និងស្ត្រី
- ចាត់វិធានការដើម្បីលើកទឹកចិត្តសមភាព និងការគោរព
- ការបង្កើតការយល់ដឹងអំពី DFSV
- ការពិភាក្សាអំពី DFSV និង
- ការកសាងភាពជាដៃគូ និងតស៊ូមតិសម្រាប់ការផ្លាស់ប្តូរដើម្បីពង្រឹងការងាររបស់ពួកគេដើម្បីបង្ការ DFSV។

យើងម្នាក់ៗមានតួនាទីដើម្បីចាត់វិធានការ។ យើងអាចជួយបង្ការ DFSV ជាមួយគ្នា។

នេះគឺជាផ្នែកមួយនៃសន្លឹកហេតុការណ៍ទាំង 4 ស្តីពី DFSV។ ដើម្បីស្វែងយល់បន្ថែមអំពីការលើកកម្ពស់សមភាពយេនឌ័រ និងការគោរពសូមមើលសន្លឹកហេតុការណ៍ 4។ ព័ត៌មានបន្ថែមស្តីអំពីការកំណត់អត្តសញ្ញាណ និងការឆ្លើយតបចំពោះ DFSV មាននៅក្នុងសន្លឹកហេតុការណ៍ 1 និង 2។

Government of South Australia

MCCSA
Multicultural Communities Council of South Australia

Women's Safety Services SA

BREAK THE CYCLE OF DOMESTIC ABUSE